ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
***

ឆ្នាំទី ៤ លេខ ២៥ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៥.៦.៩៦ ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៦/៤០ បន្ថយរយៈពេលរងទោសអោយទណ្ឌិត ១០៨១

១៥.៦.៩៦ ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៦/៤១ បន្ថយរយៈពេលរងទោសអោយទណ្ឌិត ១០៨៧

II ទីស្ដីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

០៣.៧.៩៦ អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ១០៩៣

០១.៧.៩៦ អនុក្រឹត្យលេខ ១២៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ១០៩៦

០៤.៧.៩៦ អនុក្រឹត្យលេខ ១២៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១០៩៧

២—សេចក្ដីសម្រេច

០៨.៧.៩៦ សេចក្ដីសំរេលេខ ២៥ សសរ ស្ដីពីការបង្កើតក្រុមការងារអន្តរក្រសួងសំរាប់ទទួលបងប្អូនភៀសខ្លួនខ្មែរមកពីប្រទេសឥណ្ឌូណេស៊ី ១០៩៨

០៨.៧.៩៦ សេចក្ដីសំរេចលេខ ២៦ សសរ ស្ដីពីការផ្ទេរសិទ្ធិ ១១០០

០៨.៧.៩៦ សេចក្ដីសំរេចលេខ ២៧ សសរ ស្ដីពីការផ្ទេរសិទ្ធិ ១១០១

II ការងារបណ្តាក្រសួង

១—ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សារាចរណែនាំ

០៥.៧.៩៦	សារាចរណែនាំលេខ ០១២ សណន.សហវថ ស្តីអំពីវិធានការជាក់ស្តែងមួយចំនួន សំរាប់ការអនុវត្តន៍ថវិការដ្ឋក្នុងជំហានទី ២ នៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ	១១០២

២—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

០១.៧.៩៦	ប្រកាសលេខ ៤២៩ ផក.ប្រក អនុញ្ញាតអោយលោក ល្វង ហ៊ុម ជនជាតិខ្មែរ បើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម	១១០៥
០៤.៧.៩៦	ប្រកាសលេខ ៤៣២ ផក.ប្រក អនុញ្ញាតអោយលោក នេត វ៉ែន ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកម្លាំង ១២០ សេះ	១១០៦
០៤.៧.៩៦	ប្រកាសលេខ ៤៣៣ ផក.ប្រក អនុញ្ញាតអោយលោក ប៊ូ ឡេង ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មផលិតស្ករគ្រាប់ សញ្ញា «រូបខ្លាឃ្មុំ»	១១០៧
០៤.៧.៩៦	ប្រកាសលេខ ៤៣៤ ផក.ប្រក អនុញ្ញាតអោយលោក លី ទ្រី ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ	១១០៧
០៤.៧.៩៦	ប្រកាសលេខ ៤៣៥ ផក.ប្រក អនុញ្ញាតអោយលោក ខេង គង់ ជនជាតិខ្មែរ បន្តដំណើរការឧស្សាហកម្មតូចផលិតដែកគោលសញ្ញា « ផែនដី »	១១០៨
០៤.៧.៩៦	ប្រកាសលេខ ៤៣៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី វង្ស ពិសិដ្ឋ ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៩០ សេះ	១១០៨

០៤.៧.៩៦	ប្រកាសលេខ ៤៣៧ ផក.ប្រក អនុញ្ញាតអោយលោក គាត ឆាយ ជនជាតិខ្មែរ បន្តដំណើរការឧស្សាហកម្មតូចផលិតដែកគោលសញ្ញា « ផែនដី »	១១០៩
០៨.៧.៩៦	ប្រកាសលេខ ៤៤៥ ផក.ប្រក អនុញ្ញាតអោយលោក ចាប ច័ន្ទរិទ្ធ ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូចផលិតស្រាសសញ្ញា «សេះបង្កង់ »	១១១០
០៨.៧.៩៦	ប្រកាសលេខ ៤៤៦ ផក.ប្រក អនុញ្ញាតអោយលោក គីម ឡុង ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូចផលិតស្រាសអាល់កុល យីហោ « លាងតី »	១១១០
០៨.៧.៩៦	ប្រកាសលេខ ៤៤៧ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ថៃ អ៊ីវិនិយោគទុន (THAI INVESTMENT Co.LTD តំណាងដោយលោក LAI AH LIEN សញ្ជាតិចិនតៃវ៉ាន់ បង្កើតរោងចក្រផលិតចំណីសត្វ	១១១១
០៨.៧.៩៦	ប្រកាសលេខ ៤៤៨ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន កាំសាតូបាកូ (កម្ពុជា)(KAMSA TOBACCO (CAMBODIA Co.LTD តំណាងដោយលោក ថេង ប៊ុនម៉ា បង្កើតរោងចក្រ បារីនាំចេញ	១១១២
០៨.៧.៩៦	ប្រកាសលេខ ៤៤៩ ផក.ប្រក អនុញ្ញាតអោយលោក ហៃ ហួរ ជនជាតិខ្មែរ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកអនាម័យ	១១១២
០៨.៧.៩៦	ប្រកាសលេខ ៤៥០ ផក.ប្រក អនុញ្ញាតអោយលោក លាង ហុង ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មកែច្នៃទឹកត្រី	១១១៣
០៨.៧.៩៦	ប្រកាសលេខ ៤៥១ ផក.ប្រក អនុញ្ញាតអោយលោក ជា ហេង ជាប្រធានរោងម៉ាស៊ីនកិនស្រូវ ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក អេង ហេងលី វិញ	១១១៤

០៨.៧.៩៦ ប្រកាសលេខ ៤៥២ ផក.ប្រក អនុញ្ញាតអោយលោក អៀង សុង ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវសញ្ញា «ត្បូងពេជ្រ » ១១១៤

០៨.៧.៩៦ ប្រកាសលេខ ៤៥៣ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ទាវ គីម លាន ជនជាតិខ្មែរ ជាម្ចាស់ឧស្សាហកម្មតូចផលិតថ្នាំលាបផ្ទេរសិទ្ធិ គ្រប់គ្រងជូនលោក សុខ វិសា វិញ ១១១៥

០៨.៧.៩៦ ប្រកាសលេខ ៤៥៤ ផក.ប្រក អនុញ្ញាតអោយលោក ពេជ សំអាង ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធសញ្ញា «រូបព្រះច័ន្ទពេញវង់» ១១១៦

២–ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

០២.៧.៩៦ ប្រទេសលេខ ១៩៩/៩៦ ពម.បសទ.ប្រក អនុញ្ញាតអោយលោក កុក ម៉េង បើកស្ថានីយ៍វិទ្យុផ្សាយសំលេង FM 89 MHZ ១១១៧

០២.៧.៩៦ សេចក្តីសំរេចលេខ ២០០/៩៦ ពម.សសរ ស្តីពីការបង្កើតអនុគណៈ កម្មការបច្ចេកទេសកែទម្រង់រដ្ឋបាល ប្រចាំក្រសួងពតិមាន ១១១៨

០៣.៧.៩៦ ប្រកាសលេខ ២០១/៩៦ ពម.បសទ.ប្រក អនុញ្ញាតជូនលោក ប៊ុន ចាន់ បើកអាជីវកម្មរោងពុម្ពឈ្មោះ «អង្គរ» ១១២០

០៣.៧.៩៦ ប្រកាសលេខ ២០២/៩៦ ពម.បល.ប្រក ស្តីពីការតែងតាំង មន្ត្រីរាជការ ១១២១

០៤.៧.៩៦ ប្រកាសលេខ ២០៨/៩៦ ពម.មពប្រក អនុញ្ញាតអោយទស្សនាវដ្តី ឈ្មោះ «កងរាជអាវុធហត្ថ» បោះពុម្ពចែកផ្សាយ ១១២២

០៥.៧.៩៦ ប្រកាសលេខ ២០៩/៩៦ ពម.បសទ.ប្រក អនុញ្ញាតជូនលោក ហុង ណារ៉ា បើកអាជីវកម្មរោងពុម្ពឈ្មោះ «ហុងណារ៉ា» ១១២៣

០៥.៧.៩៦ ប្រកាសលេខ ២១៧/៩៦ ពម.មពប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១១២៥

០៨.៧.៩៦ ប្រកាសលេខ ២១៨/៩៦ ពម.មពប្រក អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ WEEKLY MARKET បោះពុម្ពចែកផ្សាយ ១១២៦

៤—ឯកសារក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

៨.៦.៩៦ ប្រកាសលេខ ៦២៨ អយក.ប្រក ស្តីពីការកំណត់មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ លើកទី ២ ១១២៨

៥—ឯកសាររដ្ឋមន្ត្រី ក្រសួងបរិស្ថាន

ប្រកាស

០១.៧.៩៦ ប្រកាសលេខ ១០៥៧ បស្ក ស្តីពីការតែងមន្ត្រីរាជការ ១១៣១

៦—ឯកសាររដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

០៣.៧.៩៦ ប្រកាសលេខ ១១៨ ប្រក.វវស.ប ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យប្រធានបទសំរាប់ការប្រឡងបញ្ចប់បរិញ្ញាប័ត្រជំនាន់ទី ២ ឆ្នាំសិក្សា ១៩៩៥–៩៦ របស់មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ១១៣៣

៧—ឯកសារក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

៤.៧.៩៦ សេចក្តីសំរេចលេខ ១៣៣/៩៦ កធស ស្តីពីការអនុញ្ញាតអោយសាងសង់វិហារឥស្លាមភូមិទ្រាទី ២ ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ១១៣៤

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៦៩៦/៩០

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០_៦_១៩៨៨

* * *

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ១២ ខែ អោយទណ្ឌិតចំនួន ១៩ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម

១_ទណ្ឌិតឈ្មោះ **ឡុង សឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ២៤_៨_១៩៨៩ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

២_ទណ្ឌិតឈ្មោះ **ឈើយ ឆេន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាម អំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី ១០_១០_១៩៨៩ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៣_ទណ្ឌិតឈ្មោះ **អួរ ថ្នក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាម អំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី ១០_១០_១៩៨៩ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៤_ទណ្ឌិតឈ្មោះ **អ៊ុន សឿ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាម អំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ១១_៤_១៩៨៨ របស់តុលាការខេត្តសៀមរាប ឧត្តរ មានជ័យ ។

៥_ទណ្ឌិតឈ្មោះ **សាន ផាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៧_០១_១៩៨៨ របស់តុលាការខេត្តស្វាយរៀង ។

៦_ទណ្ឌិតឈ្មោះ **សៀន យ៉ុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ០៤_១០_១៩៨៨ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៧_ទណ្ឌិតឈ្មោះ **ឃួន ខេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាម អំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ១៣_៧_១៩៨៨ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៨_ទណ្ឌិតឈ្មោះ **សែត វណ្ណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាម អំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ០៣_៣_១៩៩២ របស តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៩_ទណ្ឌិតឈ្មោះ **ដួង ជឹម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ០៣_៣_១៩៩២ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

១០_ទណ្ឌិតឈ្មោះ **ញឹម អិត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ០៣_១១_១៩៨៨ របស់តុលាការខេត្តកំពង់ស្ពឺ ។

១១_ទណ្ឌិតឈ្មោះ **មូល ស៊ិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ១១_១០_១៩៨៦ របស់តុលាការខេត្តកំពត ។

១២_ទណ្ឌិតឈ្មោះ **តាន់ ម៉ូ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី ១៩_៩_១៩៨៥ របស់តុលាការខេត្តកំពត ។

១៣_ទណ្ឌិតឈ្មោះ **ឈុម ខ៊ាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំតាមអំណាចសាលក្រមលេខ ១ ចុះថ្ងៃទី ២៨_០២_១៩៨៤ របស់តុលាការខេត្តកំពត ។

១៤_ទណ្ឌិតឈ្មោះ **មាស ចាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី ៣០_៨_១៩៨៦ របស់តុលាការខេត្តកំពត ។

១៥_ទណ្ឌិតឈ្មោះ **យឹម ហ៊ើន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ២៧_៦_១៩៨៧ របស់តុលាការខេត្តកំពត ។

១៦_ទណ្ឌិតឈ្មោះ **ម៉ៀម ទ៊ុត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី ៣០_៨_១៩៨៦ របស់តុលាការខេត្តកំពត ។

១៧_ទណ្ឌិតឈ្មោះ **សុខ ហ៊ុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ១៤_១២_១៩៨៧ របស់តុលាការខេត្តកំពត ។

១៨_ទណ្ឌិតឈ្មោះ **ស៊ិន ឆ្លេន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ១៩_៦_១៩៨៥ របស់តុលាការខេត្តកំពត ។

១៩_ទណ្ឌិតឈ្មោះ **នង ផ៉ិត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ២៨_១១_១៩៨៥ របស់តុលាការខេត្តកំពត ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៩ ខែ អោយទណ្ឌិតចំនួន ៦ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ហ៊ុន ពៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ០៤_០២_១៩៩១ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

២_ទណ្ឌិតឈ្មោះ **ឃ្លោក ផល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១ ចុះថ្ងៃទី ១៦_០២_១៩៨៨ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៣_ទណ្ឌិតឈ្មោះ **ឆម ឈត់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ១៤_០២_១៩៩២ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៤_ទណ្ឌិតឈ្មោះ **សៅ នន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ១៨_៨_១៩៩០ របស់តុលាការខេត្តស្វាយរៀង ។

៥_ទណ្ឌិតឈ្មោះ **សំ សារិត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ២៨_១២_១៩៩០ របស់តុលាការខេត្តស្វាយរៀង ។

៦_ទណ្ឌិតឈ្មោះ **សួន និត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៦_៦_១៩៩០ របស់តុលាការខេត្តកំពត ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៦ ខែ អោយទណ្ឌិតចំនួន ៦ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ស៊ា សារិទ្ធហៅ ខូ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៨ ចុះថ្ងៃទី ១៨_៨_១៩៩៥ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

២_ទណ្ឌិតឈ្មោះ **អេខ ស៊ឿ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ២៩_៩_១៩៩៣ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៣_ទណ្ឌិតឈ្មោះ **ម៉ែន ជឿន ហៅ មឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ ចុះថ្ងៃទី ២៨_៤_១៩៩៥ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៤_ទណ្ឌិតឈ្មោះ **ខៃ មុត** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ០២_៧_១៩៩២ របស់តុលាការខេត្តកំពង់ស្ពឺ ។

៥_ទណ្ឌិតឈ្មោះ **ទី នី** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២៤_០១_១៩៩៤ របស់តុលាការខេត្តកំពង់ស្ពឺ ។

៦_ទណ្ឌិតឈ្មោះ **ដួង ពើម** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ១២_៥_១៩៩៣ របស់តុលាការខេត្តកំពត ។

មាត្រា ៤ : ត្រូវលើកលែងទោសអោយទណ្ឌិតចំនួន ១៥នាក់ ដែលបានខិតខំអប់រំកែប្រែ ខ្លួនបានល្អក្នុងរយៈពេលរងទោសកន្លងមកដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **លន់ ស៊ន់** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៧_៦_១៩៨៧ របស់តុលាការខេត្តសៀមរាប ឧត្តរ មានជ័យ ។

២_ទណ្ឌិតឈ្មោះ **ម្នាង ទ៊ាន់ផុត** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩ ចុះថ្ងៃទី ៣០_៦_១៩៩៣ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ។

៣_ទណ្ឌិតឈ្មោះ **ចាន់ សារ៉ាត** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ០២_៤_១៩៩៤ របស់តុលាការខេត្តស្វាយរៀង ។

៤_ទណ្ឌិតឈ្មោះ **រស់ ឡឿន** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ ០១ ខែ តាមអំណាចសាលក្រមលេខ ៩ ចុះថ្ងៃទី ០៩_៩_១៩៩៥ របស់តុលាការខេត្តស្វាយរៀង ។

៥_ទណ្ឌិតឈ្មោះ **ឡើត នី** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៧ ចុះថ្ងៃទី ២៣_១២_១៩៩៤ របស់តុលាការខេត្តកំពង់ស្ពឺ ។

៦_ទណ្ឌិតឈ្មោះ **សុវត្ថិ ផល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ ចុះថ្ងៃទី ១៦_៧_១៩៩៤ របស់តុលាការខេត្តកំពង់ស្ពឺ ។

៧_ទណ្ឌិតឈ្មោះ **ហែម សំណាង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥
ចុះថ្ងៃទី ១៦_៧_១៩៩៤ របស់តុលាការខេត្តកំពង់ស្ពឺ ។

៨_ទណ្ឌិតឈ្មោះ **ស៊ិន សម្បត្តិ ហៅ ឡេង សុវណ្ណារ៉ា** ដែលត្រូវបានផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ០៦_៧_១៩៩៤ របស់ តុលាការខេត្តកំពង់ស្ពឺ ។

៩_ទណ្ឌិតឈ្មោះ **តាំង ស្រ៊ិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៧ ចុះថ្ងៃទី ៣០_៩_១៩៩៤ របស់តុលាការខេត្តកំពង់ស្ពឺ ។

១០_ទណ្ឌិតឈ្មោះ **ពុំ ម៉ី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ០៧_០១_១៩៩៤ របស់តុលាការខេត្តកំពង់ស្ពឺ ។

១១_ទណ្ឌិតឈ្មោះ **ង៉ាង គុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២៦_៦_១៩៨៧ របស់តុលាការខេត្តកំពត ។

១២_ទណ្ឌិតឈ្មោះ **ជួន សុមោង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២៧_៤_១៩៩៥ របស់តុលាការខេត្តកំពត ។

១៣_ទណ្ឌិតឈ្មោះ **អៀង ជឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧២ ចុះថ្ងៃទី ០៨_៩_១៩៩៤ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

១៤_ទណ្ឌិតឈ្មោះ **អ៊ុន សំអាត** ហៅចែ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ២៨_១២_១៩៩០ របស់តុលាការខេត្តស្វាយរៀង ។

១៥_ទណ្ឌិតឈ្មោះ ឌុំយ ឆៀន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី ០៣_១១_១៩៨៨ របស់តុលាការខេត្តកំពង់ស្ពឺ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះមានអានុភាព អនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៦ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និង ក្រសួងមហាផ្ទៃត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៦៩៦/៤១

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០_៦_៨៨

* * *

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលជាប់ពន្ធនាគារ ពីអស់មួយជីវិតមកត្រឹម ២០ ឆ្នាំ អោយទណ្ឌិតចំនួន ០១ នាក់ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយឈ្មោះខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ហួន ស៊ីម** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ អស់មួយជីវិតតាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ២៤_៥_១៩៨៩ របស់តុលាការខេត្តកំពង់ធំ ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ អោយទណ្ឌិតចំនួន ១២ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមាននាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ចាន់ គុយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ២៨_៨_១៩៨៧ របស់តុលាការខេត្តកំពង់ធំ ។

២_ទណ្ឌិតឈ្មោះ **សួ ខួន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ២២_៣_១៩៨៦ របស់តុលាការខេត្តកំពង់ធំ ។

៣_ទណ្ឌិតឈ្មោះ **ម៉ោង សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៦_៩_១៩៨៩ របស់តុលាការខេត្តកំពង់ធំ ។

៤_ទណ្ឌិតឈ្មោះ **ហេង ឆៃ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៨_៨_១៩៨៧ របស់តុលាការខេត្តកំពង់ធំ ។

៥_ទណ្ឌិតឈ្មោះ **ឈៅ ឈាក់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ២៩_១១_១៩៨៥ របស់តុលាការខេត្តបាត់ដំបង ។

៦_ទណ្ឌិតឈ្មោះ **ឡូញ ឡេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១ ចុះថ្ងៃទី ២៦_០២_១៩៨៧ របស់តុលាការខេត្តបាត់ដំបង ។

៧_ទណ្ឌិតឈ្មោះ **អ៊ឹម ថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ០៦_០២_១៩៨៩ របស់តុលាការខេត្តបាត់ដំបង ។

៨_ទណ្ឌិតឈ្មោះ **ម៉ន ម៉េត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ០៦_០២_១៩៨៩ របស់តុលាការខេត្តបាត់ដំបង ។

៩_ទណ្ឌិតឈ្មោះ **ខៀវ ដេត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០៨ ចុះថ្ងៃទី ២៦_៥_១៩៨៨ របស់តុលាការខេត្តបាត់ដំបង ។

១០_ទណ្ឌិតឈ្មោះ **គួន ឡូញ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ០២_៩_១៩៩១ របស់តុលាការខេត្តបាត់ដំបង ។

១១_ទណ្ឌិតឈ្មោះ **យង់ ដារ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ២៩_៨_១៩៩១ របស់តុលាការខេត្តបាត់ដំបង ។

១២_ទណ្ឌិតឈ្មោះ **យឹម សាមុត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ ចុះថ្ងៃទី ០៧_១១_១៩៩១ របស់តុលាការខេត្តបាត់ដំបង ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៩ ខែ អោយទណ្ឌិតចំនួន ៣ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ញឹក គង់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ១៣_៨_១៩៨៧ របស់តុលាការខេត្តបាត់ដំបង ។

២_ទណ្ឌិតឈ្មោះ **ស៊ិន សិរីវុឌ្ឍ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩ ចុះថ្ងៃទី ២៤_៥_១៩៩០ របស់តុលាការខេត្តបាត់ដំបង ។

៣_ទណ្ឌិតឈ្មោះ **ខួន ឆលាង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ២០_៥_១៩៩២ របស់តុលាការខេត្តបាត់ដំបង ។

មាត្រា ៤ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៦ ខែ អោយទណ្ឌិតចំនួន ៩ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ស៊ូ ស្រី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ០៣_៥_១៩៩៥ របស់តុលាការក្រុងព្រះសីហនុ ។

២_ទណ្ឌិតឈ្មោះ **គង់ វណ្ណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ខែ តាមអំណាចសាលក្រមលេខ ៣៥ ចុះថ្ងៃទី ១៨_៧_១៩៩៥ របស់តុលាការក្រុងព្រះសីហនុ ។

៣_ទណ្ឌិតឈ្មោះ **ហង់ ពេញ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាម អំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ២២_០២_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៤_ទណ្ឌិតឈ្មោះ **មុំ ខ្លូច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ១៩ ចុះថ្ងៃទី ២៣_០២_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៥_ទណ្ឌិតឈ្មោះ **សោម សុគន្ធា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាម អំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ១៣_៨_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៦_ទណ្ឌិតឈ្មោះ **សុខ សាម៉ន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០ ចុះថ្ងៃទី ២១_៩_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៧_ទណ្ឌិតឈ្មោះ **ឡៀន ឡឿ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ២៩_១១_១៩៨៩ របស់តុលាការខេត្តកំពង់ធំ ។

៨_ទណ្ឌិតឈ្មោះ **ម៉ែន ម៉ៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ២៦_១០_១៩៨៩ របស់តុលាការខេត្តកំពង់ធំ ។

៩_ទណ្ឌិតឈ្មោះ **យាន គី** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី ២៩_០១_១៩៩៤ របស់តុលាការខេត្តកំពង់ធំ ។

មាត្រា ៥ : ត្រូវលើកទោសអោយទណ្ឌិតចំនួន ១៤ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសកន្លងមកដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **សំ ថន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាច សាលក្រមលេខ ១៥ ចុះថ្ងៃទី ៣០_៤_១៩៩៣ របស់តុលាការក្រុងព្រះសីហនុ ។

២_ទណ្ឌិតឈ្មោះ **ស៊ឹម អ៊ិច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ១៥_០១_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៣_ទណ្ឌិតឈ្មោះ **នួន ផល្លា** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ២២_០២_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៤_ទណ្ឌិតឈ្មោះ **មិល មុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី ២៣_៣_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៥_ទណ្ឌិតឈ្មោះ **សេខ ម៉ុនធឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ ចុះថ្ងៃទី ១៦_១១_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៦_ទណ្ឌិតឈ្មោះ **ចាប ភ្លើន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨២ ចុះថ្ងៃទី ៣០_១១_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៧_ទណ្ឌិតឈ្មោះ **សុខ វណ្ណៈ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨២ ចុះថ្ងៃទី ៣០_១១_១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៨–ទណ្ឌិតឈ្មោះ ទិត ទៅ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ខែ តាមអំណាចសាលក្រមលេខ ៦៧ ចុះថ្ងៃទី ០៩–១២–១៩៩៥ របស់តុលាការក្រុងព្រះសីហនុ ។

៩–ទណ្ឌិតឈ្មោះ ជឿម ជំនួរ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ... ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ១០–០១–១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ។

១០–ទណ្ឌិតឈ្មោះ ទ្រឹក ផុល ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៦–៩–១៩៨៩ របស់តុលាការខេត្តកំពង់ធំ ។

១១–ទណ្ឌិតឈ្មោះ ឡូ សារ៉ាត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ ចុះថ្ងៃទី ២៧–០២–១៩៩៥ របស់តុលាការក្រុងភ្នំពេញ ។

១២–ទណ្ឌិតឈ្មោះ មិន សារី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ ចុះថ្ងៃទី ២៧–០២–១៩៩៥ របស់តុលាការក្រុងភ្នំពេញ ។

១៣–ទណ្ឌិតឈ្មោះ អ៊ែម រីន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ០៨–៤–១៩៨៨ របស់តុលាការខេត្តបាត់ដំបង ។

១៤–ទណ្ឌិតឈ្មោះ ឌួន ឆា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៤ ចុះថ្ងៃទី ១១–១០–១៩៩៥ របស់តុលាការក្រុងព្រះសីហនុ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះមានអនុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៧ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និង ក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

II ទីស្ដីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

ភ្នំពេញ,ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣៣ អនក្រ.បក

ស្ដីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំ

និងអនុវត្តនយោបាយកិច្ចការព្រៃឈើ

* *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញក្រឹត្យ–ច្បាប់ ៣៥ ក្រច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្ដីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា–ប្រមាញ់និងនេសាទ

សំរេច

មាត្រា ១ : បង្កើតគណៈកម្មាធិការជាតិមួយ ដែលមានឈ្មោះថា « គណៈកម្មាធិការជាតិរៀបចំនិងអនុវត្តនយោបាយកិច្ចការព្រៃឈើ » ។

មាត្រា ២ : គណៈកម្មាធិការជាតិរៀបចំនិងអនុវត្តនយោបាយកិច្ចការព្រៃឈើមាន សមាសភាពដូចខាងក្រោម ÷

១_សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី ១	សហប្រធាន
២_សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២	សហប្រធាន
៣_ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សហអនុប្រធាន
៤_រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សហអនុប្រធាន
៥_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៦_តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៧_តំណាងក្រសួងការពារជាតិ	សមាជិក
៨_តំណាងក្រសួងមហាផ្ទៃ	សមាជិក
៩_តំណាងក្រសួងផែនការ	សមាជិក
១០_តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
១១_តំណាងក្រសួងបរិស្ថាន	សមាជិក
១២_លោកប្រធាននាយកដ្ឋានរុក្ខាប្រមាញ់	លេខាធិការប្រតិបត្តិ

មាត្រា ៣ : គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ មានលេខាធិការដ្ឋានមួយជាជំនួយការ ដឹកនាំដោយលេខាធិការប្រតិបត្តិនៃ គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ស្ថិតនៅក្រោមអាណាព្យាបាលក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ។ សមាជិកនៃលេខាធិការដ្ឋានត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ តាមសំណើរបស់លេខាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ ។

មាត្រា ៤ : គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ មានសិទ្ធិប្រើប្រាស់ត្រារបស់រាជរដ្ឋាភិបាល ។

- លេខាធិការដ្ឋាន នៃ គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

មាត្រា ៥ : គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ដំណើរការក្រោមការឧបត្ថម្ភរបស់ថវិកាជាតិ និង ជំនួយរបស់សហគមន៍អន្តរជាតិ ។

មាត្រា ៦ : គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ត្រូវទទួលបន្ទុកកំណត់ទស្សនៈទានតាមដាន និង វាយតំលៃលើនយោបាយព្រៃឈើ នៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងក្របខ័ណ្ឌនេះគណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ មានភារកិច្ចសំខាន់ ៗ គឺ ÷

- សំរបសំរួលកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល និង ជំនួយអន្តរជាតិលើបញ្ហានយោបាយព្រៃ ឈើ ។
- ជ្រើសរើសនិងគ្រប់គ្រងជំនួយបច្ចេកទេសពីក្រៅ ។
- សំរបសំរួលកិច្ចប្រឹក្សារវាងបណ្តាផ្នែកពាក់ព័ន្ធទាំងអស់ក្នុងវិស័យព្រៃឈើ ។
- រៀបចំកម្មវិធីវិនិយោគក្នុងវិស័យព្រៃឈើ ។
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពរបស់គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើជូនរាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយ ។ ក្រៅពីនេះ គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ត្រូវទទួលបន្ទុកធ្វើសំណើគ្រប់ករណី ឬ គ្រប់គំរោងផែនការ សកម្មភាពលើនយោបាយព្រៃឈើ នៃ ប្រទេសជាតិ ។

មាត្រា ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង លោកប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១២៣ អនក្រ.តត

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ។

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាសស្ថាបនាជាតិ ជូនចំពោះលោក **ចេង ឈាន់ម៉ុង** តំណាងក្រុមហ៊ុន « YUAN TA GROUP » ដែលបានបរិច្ចាគប្រាក់ចំនួន ១៨.០០០ $US សំរាប់កសាង សាលាបឋមសិក្សា បាក់ខែង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១២៤ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ. ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង អភិបាលរងខេត្ត – ក្រុង
- យោងសំណើរបស់ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : តែងតាំងលោក **ជាញ់ អាន** ជាអភិបាលរងទី ៣ ខេត្តក្រចេះ ជំនួសលោក **ឡាក់ ស៊ីមហ៊ា** ដែលត្រូវផ្លាស់អោយមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ព្រមទាំង សាម៉ីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន

ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២—សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ២៥ សសរ

ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងសំរាប់ទទួល បងប្អូនជនភៀសខ្លួនខ្មែរ មកពីប្រទេសឥណ្ឌូនេស៊ី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : បង្កើតក្រុមការងារអន្តរក្រសួងមួយ ដែលមានសមាសភាពដូចខាងក្រោម ÷

១–តំណាងក្រសួងមហាផ្ទៃ	ប្រធាន
២–តំណាងកាកបាទក្រហមកម្ពុជា	អនុប្រធាន
៣–តំណាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក

៤-តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៥-តំណាងក្រសួងសុខាភិបាល សមាជិក

៦-មន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២ រូប សមាជិក

ប្រការ ២ : ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

-សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រៀមរៀបចំជំរុំបណ្តោះអាសន្នមួយ សំរាប់ទទួលបងប្អូនជនភៀសខ្លួនខ្មែរចំនួន ៣១៨ នាក់ មកពីជំរុំ ហ្គាឡង់ ប្រទេសឥណ្ឌូនេស៊ី ។

-លើកគំរោងថវិកា សំរាប់ចំណាយ

-កាកបាទក្រហមធ្វើការទំនាក់ទំនងជាមួយ UNHCR ដើម្បីសុំអោយ អង្គការនេះជួយ ឧបត្ថម្ភបងប្អូនជនភៀសខ្លួនខ្មែរទាំង ៣១៨ នាក់ រហូតដល់គោលដៅចុងក្រោយ ដែល មានទីតាំងរស់នៅលើទឹកដីកម្ពុជា ។

-លើកគំរោងសុំការសំរេចពីរាជរដ្ឋាភិបាល ក្នុងករណីដែលក្រុមការងារមិនអាចដោះស្រាយបាន ។

-រាយការណ៍អំពីលទ្ធផលការងារជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៣ : សមាជិកក្រុមការងារទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន កាកបាទក្រហមកម្ពុជា និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ២៦ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ឯកឧត្តមរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋលេខាធិការស្តីទី នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំនួសឯកឧត្តម **សូ ឃុន** ដែលត្រូវអញ្ជើញទៅ បំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦ រហូតដល់ឯកឧត្តមបញ្ចប់បេសកកម្ម ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **ស៊ុំ ម៉ានិត** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្ដីសំរេចលេខ ២៧ សសរ

ស្ដីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្ដទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្ដម **ជា ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្ដីទី នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួសឯកឧត្ដម **គាត ឈន់** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦ រហូតដល់ឯកឧត្ដមបញ្ចប់បេសកកម្ម ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្ដម **ជា ចាន់តូ** ត្រូវទទួលបន្ទុកអនុវត្ដសេចក្ដីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្ដម រណឫទ្ធិ	**ហ៊ុន សែន**

III ការងារបណ្ដាក្រសួង

១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សារាចរណែនាំ

រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៦

សារាចរណែនាំលេខ ០១២ សណន.សហវ

ស្ដីអំពីវិធានការដាក់ស្ដែងមួយចំនួនសំរាប់

ការអនុវត្តថវិការដ្ឋ ក្នុងជំហានទី ២

នៃកំណែទម្រង់ ហិរញ្ញវត្ថុសាធារណៈ

ផ្អែកតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ និង អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៨១ អនក្រ.បក ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយត - រាជធានីភ្នំពេញ និង អង្គការសាធារណ រដ្ឋបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញជាប្រកាស និង សារាចរណែនាំ បន្ទាប់មានដូចតទៅនេះ :

១ - ប្រកាសលេខ ០០៥ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ។

២ - សារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្ដីអំពីរដ្ឋទេយ្យចំណូល ។

៣ - សារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្ដីអំពី រដ្ឋទេយ្យបុរេប្រទាន ។

៤ - សេចក្ដីណែនាំលេខ ០០៤ សហវ.ម ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ភ្នាក់ងារបើក ផ្តល់ ។

៥ - សារាចរណែនាំលេខ ០០៦ សហវ.ម ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៦ ស្ដីអំពីទម្រង់ ការទូទៅដើម្បីអនុវត្តថវិការដ្ឋទៅតាមបទបញ្ញាថ្មី ស្ដីពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យ ។

៦- សារាចរណែនាំលេខ ០០៧ សហវ.ម ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីអំពីវិច័យ និង ឥលនាតិណាទាន ។

៧- សេចក្តីណែនាំលេខ ០០៩ សហវ.ម ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីអំពីនីតិវិធី និងបរិបថចំណាយថវិកា ។

ដើម្បីធានាសុពលភាពនៃដំណើរការអនុវត្តថវិកា ប្រព្រឹត្តទៅអោយកាន់តែទទួលបានលទ្ធផលល្អ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានវិធានការណ៍ជាក់ស្តែងមួយចំនួនចំពោះ មុខដូចតទៅនេះ :

១/- ការធ្វើអាណត្តិកិច្ចចំណាយ :

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់យកថ្ងៃ ០១ ខែ កក្កដា ឆ្នាំ ១៩៩៦ ជាថ្ងៃចាប់ផ្តើមការអនុវត្តន៍កិច្ចប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋតាមគោលការណ៍កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជំហានទី ២ ដូច្នេះរាល់សំណុំលិខិតស្នើឥណទានរបស់ក្រសួងស្ថាប័ន ដែលបានបញ្ជូនមកដល់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មុនរយៈពេលកំណត់ខាងលើ និង រាល់សំណើឥណទានរបស់ក្រសួងស្ថាប័ន ដែលបញ្ជូនមកនៅចន្លោះពេលថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានធ្វើប្រកាសតែងតាំងមន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុនោះ ការធ្វើអាណត្តិកិច្ចចំណាយ (Mandat) គឺបន្តធ្វើនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ក្រោយពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញប្រកាសតែងតាំង មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ ក្រសួងស្ថាប័នសាមីមានភារៈទទួលខុសត្រូវធ្វើអាណត្តិកិច្ចចំណាយ ដោយផ្អែកតាមស្មារតីនៃ សេចក្តីណែនាំលេខ ០០៩ សហវ.ម ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីអំពីនីតិវិធី និង បរិបថចំណាយថវិកា ។

ក្រសួងស្ថាប័នត្រូវធ្វើអាណត្តិកិច្ចចំណាយចំនួន ០៧ ច្បាប់

- ទុកឯកសារនៅក្រសួងស្ថាប័ន ១ ច្បាប់
- មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ ១ ច្បាប់
- នាយកដ្ឋានថវិកា (ក្រោយពេលចុះទិដ្ឋាការរបស់មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុរួច) ១ ច្បាប់
- រតនាគារជាតិ ៤ ច្បាប់

២/- ការពិនិត្យផ្តល់ឥណទានចំណាយ :

រាល់សំណើឥណទានរបស់ក្រសួងស្ថាប័ន ជាប្រាក់រៀលក្តី ជារូបិយប័ណ្ណក្តី ជាដំបូង បង្ហូសត្រូវឆ្លងកាត់មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ ។ ចំពោះសំណើឥណទានសាងសង់ ទព្វសំភារៈ និង ឥណទានជារូបិយប័ណ្ណ មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ ត្រូវបញ្ជូនមក នាយកដ្ឋានពាក់ព័ន្ធ (នាយកដ្ឋានហិរញ្ញវត្ថុ ក្រៅប្រទេស នាយកដ្ឋានគ្រប់គ្រងទុនវិនិយោគ និង ស្ថាបនាមូលដ្ឋាន) ដើម្បីពិនិត្យអោយបានទាន់ពេលវេលា ។

ដើម្បីប្រតិបត្តិអោយមានប្រសិទ្ធភាពតាមស្មារតីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលថ្មីនេះ ការផ្សារភ្ជាប់ពីភាពជាក់ស្តែងទៅនឹងសភាពការណ៍សេដ្ឋកិច្ចហិរញ្ញវត្ថុ និង ថវិកាពេលបច្ចុប្បន្នគឺជាប្រការចាំបាច់បំផុត ។ ពិនិត្យលើតុល្យភាពរវាងស្ថានភាពចំណូល ចំណាយ ថវិការដ្ឋទៅនឹងស្ថានភាព ចំណូល ចំណាយសាច់ប្រាក់នៃធនាគារជាតិ ឃើញថា ការបាត់តុល្យភាពជាប្រចាំ នាំមកនូវកង្វះសាច់ប្រាក់សំរាប់ចំណាយ និង ការទូទាត់ក្នុង ដំណើរការចំណាយរដ្ឋបាល ។

វិធានការណ៍ចំពោះមុខសំរាប់ដោះស្រាយ និនភាពសាច់ប្រាក់នៃធនាគារជាតិ គឺវិធីតុល្យភាព ចំណូល ចំណាយថវិកាដោយឈរលើគោលការណ៍ មានចំណូលទើប ចំណាយ ។

ផ្តើមចេញពីនេះ រាល់សំណើឥណទានចំណាយដំណើរការរដ្ឋបាល សំភារៈ ជួសជុលតូចនិង សាងសង់ទព្វសំភារៈ ក្រៅពីជំពូក ១០ របស់ក្រសួងស្ថាប័នជាប្រាក់រៀលក្តី ជារូបិយប័ណ្ណក្តីដែលលើសពី កំរិតកំណត់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនោះ មន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុ រឺ នាយកដ្ឋាន ហិរញ្ញវត្ថុក្រៅប្រទេស រឺ នាយកដ្ឋាន គ្រប់គ្រងទុនវិនិយោគស្ថាបនាមូលដ្ឋានត្រូវសុំសេចក្តីសំរេចពីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយឆ្លងកាត់នាយកដ្ឋានថវិការដ្ឋ ដើម្បីពិនិត្យតុល្យភាពចំណូលចំណាយថវិកា សំដៅអោយ អាណត្តិកិច្ច ចំណាយ ដែលបញ្ជូនដល់ធនាគារជាតិធានាមានសាច់ប្រាក់ ។

ចំពោះសំណើឥណទានចំណាយរបស់ក្រសួងស្ថាប័ន សំរាប់ផ្តល់ឥណទានបន្ថែម ទៅអោយមន្ទីរ ជំនាញជាខ្សែបណ្តោយរបស់ខ្លួននៅខេត្ត - ក្រុង ត្រូវមានការយល់ព្រមពីមន្ត្រី ធ្វើការងារអភិបាលហិរញ្ញវត្ថុជាមុន ទើបបញ្ជូនមកនាយកដ្ឋានថវិកាដើម្បីពិនិត្យ និង ធ្វើប្រកាសផ្ទេរឥណទាន ។

៣/- ការពិនិត្យលើសំណើនិយ័តភាពឥណទាន

នាយកដ្ឋានថវិការដ្ឋជាអង្គភាពទទួលខុសត្រូវលើការពិនិត្យរាល់សំណើនិយ័តភាពឥណទានរបស់ក្រសួងស្ថាប័ន និង មន្ទីរជំនាញនានានៅខេត្ត - ក្រុង ។ ដោយឡែករាល់សំណើនិយ័តភាពថវិកា របស់ក្រសួងស្ថាប័ន ត្រូវឆ្លងការយល់ព្រមពីរដ្ឋមន្ត្រីធ្វើការងារអភិបាលហិរញ្ញវត្ថុជាមុនសិន ។

វិធានការណ៍បន្ថែមជាច្រើនទៀត នឹងត្រូវដាក់ចេញជាបន្តបន្ទាប់ ក្រោមរូបភាពជាប្រកាស សេចក្តីណែនាំ រឺ លិខិតបទដ្ឋានផ្សេងៗ ដើម្បីបំពេញបន្ថែមអោយការអនុវត្តថវិការដ្ឋក្នុងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ អោយទទួលបានលទ្ធផលល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ។

គ្រប់ក្រសួងស្ថាប័នទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធី និង បរិបថចំណាយថវិកា ក្នុងករណីមានបញ្ហាស្មុគស្មាញ ត្រូវមកទំនាក់ទំនងដោះស្រាយជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និ ត្រា
គាត ឈន់

* * *

២—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាសលេខ ៤២៥ ឧក.ប្រក ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឈួន ហ៊ីម** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៥៤៣២ ភ.ព ចុះថ្ងៃទី ០៦–៤–៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤ ផ្លូវលេខ ១៦២ សង្កាត់ ផ្សារដេប៉ូទី១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញបើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំងភូមិក្រាំងល្ពុង ឃុំ មហាសាំង ស្រុក ភ្នំស្រួច ខេត្ត កំពង់ស្ពឺ ។

ប្រការ ២ : លោក លួច ហ៊ីង ត្រូវចាប់ផ្តើមរៀបចំសហគ្រាសរបស់ខ្លួនអោយស្រេចជាស្ថាពរ ក្នុងរយៈពេល ៦ ខែ យ៉ាងយូរ ដោយគិតចាប់តាំងពីថ្ងៃ ដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសរយៈពេលកំណត់ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវការពារសុវត្ថិភាពឧស្សាហកម្ម ជាទាបរិស្ថាន ធានាគុណភាពផលិតផលព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន។

ប្រការ ៤ : សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសោរវត្ថុ គឺ : តុ ទូ សាឡុងក្រែ អ្នារ បង្អួចឈើ ក្រឡឹងទឹរ ក្តារកៅ្ន មេកាំជណ្តើរ និង សំភារៈ ផ្សេងៗ ទៀតអំពីឈើ ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីសហគ្រាសត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់សហគ្រាសត្រូវធ្វើសេចក្តីជូនដំណឹងមកក្រសួង តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ស្ពឺ អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការ និង សកម្មភាពផលិតកម្មរបស់សហគ្រាស ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់សហគ្រាសត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើង ។

* * *

ប្រកាសលេខ ៤៣២ ឧក. ប្រក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក ឆេង ម៉េង ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៤៨៧០ ព.ស ចុះថ្ងៃទី ០៤.១១.៨៨ ជាប្រធាន អាស័យដ្ឋានមុន្តបន្ទ ក្រុមទី ២ ភូមិ ត្រពាំងជង ឃុំ ត្រពាំងជង ស្រុក បាកាន ខេត្ត ពោធិ៍សាត់ បើកដំណើរការ ផលិតកម្ម ដោយប្រើម៉ាស៊ីន កំលាំង ១២០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **នេត ទើន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៣៣ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ូ ឡេង** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨០៧៦២ ភ.ព ចុះថ្ងៃទី ២១–៣–៨៤ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២២ អឺ០ ផ្លូវលេខ ១៦៤ សង្កាត់ ផ្សារអូរឬស្សីទី ៣ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញបន្តដំណើរការសិប្បកម្មផលិតស្ករ គ្រាប់ សញ្ញា « រូបខ្លាឃ្មុំ » នៅ ក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះ នឹង ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ លេខ ៤៣៤ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **លី ទ្រី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៨៤៧៥៨ ក.ច ចុះថ្ងៃទី ១៤–៦–៨៩ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣ ភូមិ ល្អុង ឃុំ រំលេច ស្រុក បាកាន ខេត្ត ពោធិសាត់ បើកដំណើរការរោង

ម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក លី ទ្រី ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបាន កំណត់ ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៣៥ ឧក.ប្រក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ខេង គង់** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ១២២៥៨៣ ភ.ព ចុះថ្ងៃទី ០១-៦-៨២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៣៣ ផ្លូវជាតិលេខ ៥ ភូមិ ស្ពានខ្ពស់ សង្កាត់ គីឡូម៉ែត្រលេខ ៦ ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូច ផលិតដែកគោល សញ្ញា « ផែនដី » នៅក្នុងទីតាំង ផ្ទះលេខ ១០ អឺ ផ្លូវលេខ ៣៥៩ ភូមិដើម អំពិល សង្កាត់ ច្បារអំពៅទី១ ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៣៦ ឧក.ប្រក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានអ្នកស្រី **ខៀវ ពិសិដ្ឋ** ជនជាតិ ខ្មែរ

សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៩៥៦៨ ព.ស ចុះថ្ងៃទី ០៧.១០.៨៦ ជាប្រធាន អាស័យដ្ឋាន បច្ចុប្បន្ន ភូមិ លលកស សង្កាត់ លលក ស ទីរួមខេត្ត ពោធិសាត់បន្តដំណើរការផលិតកម្ម ដោយ ប្រើម៉ាស៊ីន កំលាំង ៩០ សេះ នៅក្នុង ទីតាំង ក្រុមទី ៣ ភូមិ ស្នាមព្រះ ឃុំ ស្នាមព្រះ ស្រុក បាកាន ខេត្ត ពោធិសាត់ ។

ប្រការ ២ : អ្នកស្រី វង្ស ពិសិដ្ឋ ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបាន កំណត់ ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ លេខ ៤៣៧ ឧក.ប្រក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **តាត ឆាយ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៦២៩៦ ភ.ព ចុះថ្ងៃទី ០១-០១-៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៥១៥ ផ្លូវកម្ពុជា ក្រោម សង្កាត់ ផ្សារដេប៉ូទី៣ ខ័ណ្ឌ ទួលគោករាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូច ផលិត សំបកកង់សញ្ញា « ផែនដី » នៅក្នុងទីតាំង ផ្ទះសង់ថ្មី ភូមិទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៤៥ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ចាប ច័ន្ទរិទ្ធ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣២៣២៧៩ ភ.ព ចុះថ្ងៃទី ២៥-១០-៩១ អាស័យដ្ឋាន ផ្ទះលេខ ៧៥៤ សេ ផ្លូវជាតិលេខ ២ ភូមិ ព្រែកតាឡុង សង្កាត់ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បើកដំណើរការឧស្សាហកម្ម តូច « សុរាគារមានជ័យ » ផលិតស្រាសសញ្ញា « សេះបង្កង់ » នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក ចាប ច័ន្ទរិទ្ធត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផលស្រាសសញ្ញា «សេះបង្កង់ » ស្របតាមគំរូគុណភាពនិងសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហ កម្ម រ៉ែនិង ថាមពល។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៤៤៦ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **គីម ឡុង** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥៨៣៥៧ ភ.ព ចុះថ្ងៃទី ២១-០២-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៨ ផ្លូវលេខ ១១៥ សង្កាត់ បឹងព្រលិត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើរការឧស្សាហកម្មតូច ផលិតស្រាស អាល់កុល យីហោ « លាង គី » នៅក្នុងទីតាំងភូមិ ដំណាក់ធំ សង្កាត់ ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យរាជធានីភ្នំពេញ ។

ប្រការ ២ : លោក **គីម ឡុង** ត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផលស្រាសអាល់កុលសញ្ញា « រូបស្តាំងមាស » ស្របតាមគំរូគុណភាព និង សញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហ កម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹង ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៤៧ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ថៃ អ៊ី វិនិយោគទុន (TAI .I INVESTMENT Co. LTD) តំណាងដោយលោក LAI AH LIEN សញ្ជាតិ ចិនតៃវ៉ាន់ អាយុ ៦៦ ឆ្នាំ ភេទ ប្រុស អាស័យដ្ឋាន 2F N4 ZHI CHONG ROAD 5PEITOU TAIPEI CITY, TAIWAN R.O.C កាន់លិខិតឆ្លង ដែនលេខ M 8629685 ចុះថ្ងៃទី ១០–៩–៩៣ បង្កើត « រោងចក្រផលិតចំណីសត្វ » ដែលមាន ឈ្មោះ « រោងចក្រផលិតចំណីសត្វថៃអ៊ី » មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ២១ចាស់ ភូមិលេខ ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រផលិតចំណីសត្វ ដែលបានតំកល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល « ចំណីសត្វ » ទៅតាមគំរូ និង ផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៤៨ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន កាំសា តូបាកូ (កម្ពុជា) (KAMSA TOBACCO (CAMBODIA) Co., LTD)តំណាងដោយលោក ថេង ប៊ុនម៉ា ជនជាតិខ្មែរ អាយុ ៥១ឆ្នាំ ភេទប្រុស អាស័យដ្ឋានផ្ទះលេខ ៣៥ វិថីព្រះមុនីវង្ស សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ កាន់អត្ត សញ្ញាណប័ណ្ណលេខ ៣១៩៩៥៥ ភ.ព ចុះថ្ងៃទី ២០-៩-៩១ បង្កើត « រោងចក្រផលិតបារីនាំចេញ » ដែលមានឈ្មោះ « រោងចក្រផលិតបារីកាំសាតូបាកូ កម្ពុជា » មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៣ ភូមិអង្គគ្រគៀត ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ ២ : ការសាងសង់ និងរៀបចំគ្រឿងចក្រត្រូវធ្វើទៅតាមប្លង់ ដែលបានដាក់តម្កល់នៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ៩ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល « បារី » ទៅតាមគំរូ និង ផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៤៩ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក ម៉ៅ ឃូរ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៥១៦៦០ប.ជ ចុះថ្ងៃទី ១៩-១២-៨៩ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ៤ ភូមិ ២ ឃុំកំពង់ស្វាយ ស្រុក សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកអនាម័យ និង បន្ថែមមុខផលិតផលទឹកបរិសុទ្ធ

ភ្ញីស្លាយសញ្ញា « រូបប្រាង្គ » នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ។

ប្រការ ២ : លោក **ម៉ៃ ហួរ** ត្រូវបានអនុញ្ញាតអោយផលិតបន្ថែមនូវមុខផលិតផល ទឹកបរិសុទ្ធភ្ញី ស្លាយសញ្ញា « រូបប្រាង្គ » ស្របតាមគំរូ សញ្ញាសំគាល់ដែលបាន តំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាស លេខ ៤៥០ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **លាង ហុង** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណ លេខ ១០៩៦៣៨ ភ.ព ចុះថ្ងៃទី ១៦-៤-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៥៩ ផ្លូវលេខ ៣៦៩ ភូមិ ដើមចាន់ សង្កាត់ ច្បារអំពៅទី ២ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មកែច្នៃ ទឹកត្រី នៅក្នុងទីតាំង ដូចអាស័យ ដ្ឋានខាងលើ ។

ប្រការ ២ : លោក **លាង ហុង** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ទឹកត្រីកែច្នៃ សញ្ញា «សំពៅបង្គងមួយ» « សំពៅបង្គងពីរ » និង « សំពៅត្រីពីរ » ស្របតាម គំរូសញ្ញាសំគាល់ដែល បានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹង ត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៤៥១ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ខា ហេខ** ជាប្រធានរោងម៉ាស៊ីនកិនស្រូវ ដែលមានទីតាំងនៅភូមិ ដំណាក់ហ្លួង សង្កាត់ វត្តគរ ទីរួមខេត្ត បាត់ដំបង ខេត្តបាត់ដំបង ផ្ទេរភារកិច្ចគ្រប់គ្រង ជូនលោក អេង ហេងលី វិញ ។

ប្រការ ២ : ទទួលស្គាល់លោក **អេខ ហេខលី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្ត សញ្ញាណប័ណ្ណលេខ ៣១៤៤៨៨ ភ.ព ចុះថ្ងៃទី ០៥–១០–៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិសំរោងក្នុង ឃុំសំរោងក្នុង ស្រុក ស្វាយប៉ោ ខេត្ត បាត់ដំបង ជាប្រធាន រោងម៉ាស៊ីកិនស្រូវដែលមានទីតាំង ដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៥២ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **អឿខ សុខ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២២៥១២៣ ភ.ព ចុះថ្ងៃទី ២៥–៤–៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧៦ បេ ផ្លូវលេខ ៣០៤ សង្កាត់បឹងកេងកងទី ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវ សញ្ញា « ត្បូងពេជ្រ» នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **អឿខ សុខ** ត្រូវបានអនុញ្ញាតអោយ ផលិតនូវមុខផលិតផលទឹកម៉ាហ្ស៊ីសញ្ញា « ត្បូងពេជ្រ » ទឹកស៊ីអ៊ីវសញ្ញា «ស្ពែស» «ទូកបី »និង «តីមតារភ្នំពេញ » និងបន្ថែមមុខផលិតផល មួយមុខទៀតគឺ ទឹកក្បុងសញ្ញា « ផ្ទៃគរ » ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៥៣ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឆាវ គីមឈាន** ម្ចាស់ឧស្សាហកម្មតូច ផលិតថ្នាំលាប ដែលមានទីតាំង ភូមិ បឹងឈូក សង្កាត់ គីឡូម៉ែត្រលេខ ៦ ខ័ណ្ឌ ឬស្សីកែវ រាជធានីភ្នំពេញ ផ្ទេរសិទ្ធិគ្រប់គ្រងលើឧស្សាហកម្មតូចនេះ ជូនលោក **សុខ ទិសា** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៧១០៩៥ ភ.ព ចុះថ្ងៃទី ២៣.៧.៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្លូវលេខ ១០០ ផ្ទះលេខ ៣១៥ សង្កាត់បឹងកក់ទី ២ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ទទួលស្គាល់លោក **សុខ ទិសា** ជាម្ចាស់ឧស្សាហកម្មតូច ផលិតថ្នាំលាប ដែលមានទីតាំង ភូមិបឹងឈូក សង្កាត់ គីឡូម៉ែត្រលេខ ៥ ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ៣ : លោក **សុខ ទិសា** ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្មលើមុខផលិតផល ចំនួន ៧មុខ គឺ :ថ្នាំលាបសញ្ញា « ស៊ីហ្គែម »«ហ៊ុលក្លូ » ម៉េត្រូ » បេអឹម » « សេប៉េ » « ដេដេ »និង «កាកា» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៥៤ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយឧស្សាហកម្មតូច ផលិតទឹកបរិសុទ្ធ សញ្ញា « រូបព្រះច័ន្ទពេញវង់ » ដែលមានលោក **ពេជ សំអោន** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩០៦២៨ ភ.ព ចុះថ្ងៃទី ២០–៣–៨៥ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៥៤ អឺ០ ផ្លូវហែមចៀវ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បើកដំណើរការផលិតកម្មនៅក្នុងទីតាំងផ្ទះលេខ ៥៩៥ ផ្លូវជាតិលេខ ៦ អា ភូមិ កៀនឃ្លាំង សង្កាត់ ព្រែកលៀប ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ពេជ សំអោន** ត្រូវរៀបចំឧស្សាហកម្មតូចរបស់ខ្លួនអោយស្រេចជាស្ថាពរក្នុងរយៈពេល៣ ខែ យ៉ាងយូរ គិតចាប់តាំងពីថ្ងៃ ដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : លោក **ពេជ សំអោន** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកបរិសុទ្ធ សញ្ញា «រូបព្រះច័ន្ទពេញវង់ » ស្របតាមគំរូ សញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹង ត្រូវដកហូតវិញដោយ គ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ិត ប្រាំង

* * *

៣—ឯកសារក្រសួងក្រសួងពតិមាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៩៩/៩៦ ពម.ចសន.ប្រក

អនុញ្ញាតអោយលោក គុក ម៉េង

បើកស្ថានីយ៍វិទ្យុផ្សាយសម្លេង FM 89 MHZ

រដ្ឋមន្ត្រីក្រសួងពតិមាន

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

–បានឃើញព្រះរាជក្រម សន.រកម ០១៩៦-១៤ ចុះថ្ងៃទី ២៤–០១–៩៦ ស្តីពីការបង្កើត ក្រសួងពតិមាន ។

–ពិនិត្យលើសំណើសុំច្បាប់បើកស្ថានីយ៍វិទ្យុ FM 89 Mhz អនុភាពកំលាំងផ្សាយ10Kwចុះថ្ងៃទី១២.៦.៩៦ របស់លោក **គុក ម៉េង** ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **គុក ម៉េង** បើកស្ថានីយ៍វិទ្យុផ្សាយសំលេង FM89 Mhz អនុភាពកំលាំងផ្សាយតិចជាង ឬអតិបរមា 10Kw និងកំពស់អង់តែនត្រឹមតែ ៩០ម៉ែត្រ ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍វិទ្យុផ្សាយសំលេងនេះ ត្រូវគោរពតាមកិច្ចសន្យា និង ច្បាប់បញ្ញត្តិបទបញ្ជាឬសេចក្តីណែនាំខាងផ្នែកសោតទស្សន៍ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីមិនគោរពតាមកិច្ចសន្យា សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : អគ្គនាយកវិទ្យុជាតិកម្ពុជា ប្រធាននាយកដ្ឋាន គ្រប់គ្រងការបោះពុម្ពផ្សាយសោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ មន្ទីរពត៌មានរាជធានីភ្នំពេញ និងអាជ្ញាធរដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ២០០/៩៦ ពម.សសរ

ស្តីពីការបង្កើតអនុគណៈកម្មការបច្ចេកទេស

កែទម្រង់រដ្ឋបាល ប្រចាំ ក្រសួង ពត៌មាន

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រម សន.រកម ០១៩៦.១៤ចុះថ្ងៃទី ២៤-០១-៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញលិខិតលេខ ២៦៧ សជណកបស ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញ សេចក្តីសំរេចលេខ ១៥៩-៩៦ ព.មសសរ ចុះថ្ងៃទី ១១.៦.៩៦ របស់ក្រសួងពត៌មានស្តីពីការបង្កើតគណៈកម្មការកែទម្រង់ រដ្ឋបាលប្រចាំក្រសួងពត៌មាន

-តាមការចាំបាច់របស់ក្រសួងពតិមាន

សំរេច

ប្រការ ១ : បង្កើតអនុគណៈកម្មការបច្ចេកទេសកែទម្រង់រដ្ឋបាល ដើម្បីសំរួលការងារបច្ចេកទេសជូនគណៈកម្មការកែទម្រង់រដ្ឋបាលប្រចាំក្រសួងពតិមាន :

១-លោក **ចាន់ សារុន**	អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ	ជាប្រធាន
២-លោក **ស៊ិន សុខ**	ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក	ជាអនុប្រធាន
៣-លោក **សោម ប៊ុរ៉ា**	អនុប្រធាននាយកដ្ឋានបុគ្គលិក	សមាជិកអចិន្ត្រៃយ៍
៤-លោកស្រី **នង ហឿន**	ប្រធានការិយាល័យ អា កា ប៉េ	សមាជិក
៥-លោក **ជ័យ ឌុល្លី**	អនុប្រធាននាយកដ្ឋាន	សមាជិក
៦-លោកស្រី **មាស ម៉ូលី**	អនុប្រធាននាយកដ្ឋាន	សមាជិក
៧-លោកស្រី **ឈិន មុន្នី**	នាយខុទ្ទកាល័យរដ្ឋមន្ត្រី	សមាជិក
៨-លោក **អន ឌុច**	ប្រធានការិយាល័យអគ្គាធិការដ្ឋាន	សមាជិក
៩-លោក **ជា សារុន**	ប្រធានការិយាល័យកាសែតកម្ពុជា	សមាជិក

ប្រការ ២ : អនុគណៈកម្មការមានភារកិច្ច :

-ស្រាវជ្រាវនិងរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋាននីមួយៗ ។

-ពិភាក្សាកែតម្រូវជាលំអិតអោយបានសមស្របតាមភារកិច្ចរបស់អង្គភាព ។

-ស្រាវជ្រាវ និង រៀបចំលក្ខន្តិកៈដោយឡែកនៃមន្ត្រីរាជការក្រសួង ពតិមាន ។

-ឆ្លងយោបល់ ដើម្បីដាក់ជូនគណៈកម្មការបច្ចេកទេសកែទម្រង់រដ្ឋបាលប្រចាំក្រសួងពិនិត្យសំរេច ។

-ត្រូវរៀបចំដំណើរការជាបន្ទាន់ ។

ប្រការ ៣ : លោកនាយកខុទ្ទកាល័យ លោកអគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកអគ្គនាយកនាយកដ្ឋានចំណុះ និងលោក លោកស្រី ជាសមាជិកអនុគណៈកម្មការត្រូវអនុវត្ត តាមសេចក្ដីសំរេចចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២០១/៩៦ ពម.បសឧ.ប្រក

អនុញ្ញាតអោយលោក ប៊ុន ចាន់

បើកអាជីវកម្មរោងពុម្ពឈ្មោះ « អង្គរ »

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលចុះថ្ងៃទី ០១.១១.៩៣
- បានឃើញព្រះរាជក្រមចុះថ្ងៃទី ២៤.០១.៩៦ស្តីពីការបង្កើតក្រសួងពត៌មាន ។
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ : ១២២៤/៩៤ ពម. ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ ។
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ «អង្គរ» របស់លោក **ប៊ុន ចាន់** ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ប៊ុន ចាន់** អាស័យដ្ឋានផ្ទះលេខ ២៩ ផ្លូវលេខ១០៥ សង្កាត់បឹងកេងកង ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ «អង្គរ» ទីតាំងស្ថិតនៅលំនៅស្ថានដូចខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅនឹងទំនៀមទំលាប់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិបទល្មើស ដូចមានចែងក្នុងប្រការ ២សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋាន គ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុនិងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗ ខ្លួន។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២០២/៩៦ ពម.បល.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការរៀប ចំ និងប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី

–បានឃើញព្រះរាជក្រម សន.រកម ០១៩៦.១៤ ចុះថ្ងៃទី ២៤–០១–៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន ។

–តាមការចាំបាច់របស់ក្រសួង

–ពិនិត្យលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **សុខ សារ៉េត** ជាអនុប្រធាននាយកដ្ឋានក្នុងនាយកដ្ឋាន សហប្រតិបត្តិការ អន្តរជាតិ និងពិធីការនៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ។

ប្រការ ២ : លោកនាយកខុទ្ទកាល័យ លោកអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ លោកអគ្គនាយកគ្រប់អគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និង សាមីខ្លួន ត្រូវអនុវត្ត តាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២០៨/៩៦ ពម.មពប្រក

អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ

« **កងរាជអាវុធហត្ថ** » **បោះពុម្ពចែកផ្សាយ**

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាជំពូក ៣ មាត្រា ៤១

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកមកម ០៨៩៥–០៧ ចុះថ្ងៃទី ០១–៩–៩៥

– បានឃើញសំណើសុំបោះពុម្ពទស្សនាវដ្តី «កងរាជអាវុធហត្ថ» ចុះថ្ងៃទី ២៧–២–៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ «កងរាជអាវុធហត្ថ» បោះពុម្ពចែកផ្សាយដោយមានលោក **ខែឹត ស្រៀង** ជាអ្នកទទួលខុសត្រូវលើការផ្សាយ ។ ទីស្នាក់ការស្ថិតនៅទីបញ្ជាការកងរាជអាវុធហត្ថ ផ្លូវតឹមអ៊ិលស៊ុង ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុង អត្តសញ្ញាណនៃទស្សនាវដ្តីរបស់ខ្លួនត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃមកក្រសួងពតិមានដើម្បីរង់ចាំ សេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយ បានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ទស្សនាវដ្តីចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកលទុកជាឯកសារនៅក្រសួងពតិមាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើស អំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើ សាមីខ្លួនត្រូវ ទទួលទោសត្រូវតាមច្បាប់ ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នាយកមណ្ឌលពតិមាន និងលោក **ខែឹត ស្រៀង** អ្នកទទួលខុសត្រូវលើទស្សនាវដ្តី «កងរាជអាវុធហត្ថ» ត្រូវអនុវត្តនូវ ប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៨៦

ប្រកាសលេខ ២០៩/៩៦ ពម.មពប្រក

អនុញ្ញាតជូនលោក ហុង ណារ៉ា

បើកអាជីវកម្មរោងពុម្ពឈ្មោះ « ហុង ណារ៉ា »

រដ្ឋមន្ត្រីក្រសួងពតិមាន

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

– បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

– បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន ។

– យោងលិខិត ជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១២២៤/៩៤ ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ ។

– យោងលិខិត ស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ពឈ្មោះ «**ហុង ណារ៉ា**» របស់លោក ហុង ណារ៉ា ចុះថ្ងៃទី ១៧ ខែ មិថុនាឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ហុង ណារ៉ា** អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧៩ អឺ០ វិថីម៉ៅសេទុង សង្កាត់បឹងកេងកង ៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « **ហុង ណារ៉ា** » ទីតាំងស្ថិតនៅផ្ទះលេខ ១៦ អឺ០ ផ្លូវ ៤១០ សង្កាត់បឹងកេងកង ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ការិយាល័យទំនាក់ទំនងនៅផ្ទះលេខ ៧៩ វិថីម៉ៅសេទុង សង្កាត់បឹងកេងកងទី ៣ ខ័ណ្ឌចំការមន រាជរាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របទៅនឹងទំនៀមទំលាប់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២១៧/៩៦ ពម.បសឧ.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១.១១.១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមនស.រកម ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន

-យោងតាមសំណើរបស់អគ្គនាយកទីភ្នាក់ងារសាពត៌មានខ្មែរ « អា កា ប៉េ »

-ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ០៥ រូប ជាប្រធានការិយាល័យ និង តែងតាំងមន្ត្រីរាជការចំនួន ០៧ រូប ជាអនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋាន ទីភ្នាក់ងារសារពត៌មានខ្មែរ «អា កា ប៉េ» ក្រសួងពត៌មានដូចមានរាយនាមខាងក្រោមនេះ :

១-លោក **គ្រី ហុក** ជាប្រធានការិយាល័យនិពន្ធដំណឹងភាសាបារាំង

២-លោក **ឆូ តៅ** ជាប្រធានការិយាល័យនិពន្ធដំណឹងភាសាអង់គ្លេស

៣-លោក **ឡុង ម៉ុនថន** ជាប្រធានការិយាល័យបាល

៤-លោក **នួច សារ៉ាយ** ជាប្រធានការិយាល័យបោះពុម្ព

៥-លោក **ទិន ម៉ុណ្ណា** ជាប្រធានការិយាល័យ ចែកផ្សាយ

៦-លោកស្រី **គីម សុគន្ធារី** ជាអនុប្រធានការិយាល័យនិពន្ធដំណឹងភាសាអង់គ្លេស

៧-លោកស្រី	**អ៊ូ ផលសុផា**	ជាអនុអនុប្រធានការិយាល័យនិពន្ធជំពីង ភាសាបារាំង
៨-លោក	**ចាន់ សំអុល**	ជាអនុប្រធានការិយាល័យរដ្ឋបាល
៩-លោកស្រី	**ជ័យ សាំងអាង**	ជាអនុប្រធានការិយាល័យរដ្ឋបាល
១០-លោកស្រី	**ផូ សាលី**	ជាអនុប្រធានការិយាល័យហិរញ្ញវត្ថុ និង គណនេយ្យ
១១-លោក	**ស៊ុំ សំអាត**	ជាអនុប្រធានការិយាល័យសរុប និង សហប្រតិបត្តិការអន្តរជាតិ
១២-លោក	**ខៀវ នី**	ជាអនុប្រធានការិយាល័យចែកផ្សាយ

ប្រការ ២ : លោកនាយកខុទ្ទកាល័យ លោកអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ លោកអគ្គនាយកទីភ្នាក់ងារសារពត៌មានខ្មែរ «អា កា ប៉េ» លោកប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និង សាមីខ្លួនត្រូវអនុវត្តតាមប្រកាសចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២១៨/៩៦ ពម.មព.ប្រក

អនុញ្ញាតអោយឧស្សាហ៍នាទដ្ឋីឈ្មោះ

WEEKLY MARKET ចេះពុម្ពចែកផ្សាយ

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយ ប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥–០៧ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

– បានឃើញសំណើសុំបោះពុម្ពផ្សាយទស្សនាវដ្តីឈ្មោះ WEEKLY MARKET ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ WEEKLY MARKET បោះពុម្ពផ្សាយដោយមានលោកស្រី SZOLCS' ANSZKY SZILVIA ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ១០៧ វិថីព្រះមុនីវង្ស សង្កាត់មនោរម្យ ខ័ណ្ឌ ៧ មករា ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃទស្សនាវដ្តីរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ៥ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកសារពត៌មាន និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទ ត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះ រាជាណាចក្រកម្ពុជា និងស្នើផ្តល់ទស្សនាវដ្តី ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយ មកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើស អំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងលោកស្រី SZOLCS' ANSZKY SZILVIA ជាចាងហ្វាងការផ្សាយទស្សនាវដ្តី WEEKLY MARKET ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

៤—ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៦២៨ អយក.ប្រក

ស្ដីពីការកំណត់មណ្ឌលប្រលងសញ្ញាបត្រ

មធ្យមសិក្សាកំរិតសិក្សាទី ២ លើកទី ២

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១.១១.៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤.៩០ នស.រកត ចុះថ្ងៃទី ៣១.១០.៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។

– បានឃើញច្បាប់ស្ដីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

– បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២២៣៧ សជណ.អរ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ១៩៩០ ស្ដីពីការប្ដូរឈ្មោះសាលាចំណេះទូទៅ

– បានឃើញប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡាលេខ ១១៦ អយក.ប្រក ចុះថ្ងៃ០៦–២–៩៦ ស្ដីពីការរៀបចំប្រព្រឹត្តិទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២

–យោងសំណើរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ស្ដីពីការសុំបើក មណ្ឌលប្រលងសញ្ញាប័ត្រ មធ្យមសិក្សាកំរិត ២ តាមខេត្ត–ក្រុង

សំរេច

ប្រការ ១ : មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំនេះទូទៅនិងបំពេញវិជ្ជាលើកទី២ សម័យប្រលងថ្ងៃទី ២២–៧–៨៦ ត្រូវកំនត់ដូចតទៅ ÷

I - រាជធានីភ្នំពេញមាន ៣ មណ្ឌល :

១–មណ្ឌល អនុវិ. ចតុមុខ ៣៤ បន្ទប់

២–មណ្ឌល វិ. បឹងត្របែក ២៦ បន្ទប់

៣–មណ្ឌលវិ. ព្រះស៊ីសុវត្ថិ ៦០ បន្ទប់ ក្នុងនោះបំ.វិ. ៦ បន្ទប់ និង ស្ម័យរិន ១២ បន្ទប់

II - ខេត្តកណ្ដាលមាន ២ មណ្ឌល :

១–មណ្ឌល ជ័យវរ្ម័នទី ៧ ២៥ បន្ទប់

២–មណ្ឌល បឋម. ដីឥដ្ឋ ១២ បន្ទប់ ក្នុងនោះបំ.វិ ១ បន្ទប់

III - ខេត្តតាកែវ មាន ១ មណ្ឌល :

១–មណ្ឌលវិ. ជាស៊ីមតាកែវ ២០ បន្ទប់ ក្នុងនោះស្ម័យរិន ២ បន្ទប់

IV - ខេត្តកំពតមាន ១ មណ្ឌល :

១–មណ្ឌលវិ. ព្រះរាជសម្ភារ ១៥ បន្ទប់

V - ក្រុងព្រះសីហនុ មាន ១ មណ្ឌល :

១–មណ្ឌល អនុវិ. សម្ដេចឳ ៥បន្ទប់

VI - ខេត្តកំពង់ស្ពឺមាន ១ មណ្ឌល :

១–មណ្ឌល វិ. កំពង់ស្ពឺ ៦ បន្ទប់ ក្នុងនោះស្ម័យរិន ២ នាក់

VII - ខេត្តព្រៃវែង មាន ១ មណ្ឌល :

១–មណ្ឌលវិទ្យាល័យព្រះអង្គឌួង ២០ បន្ទប់ ក្នុងនោះ ស្ម័យរិន ២ បន្ទប់

VIII - ខេត្តស្វាយរៀង មាន ១ មណ្ឌល :

១–មណ្ឌលវិ. ស្វាយរៀង ១១ បន្ទប់

IX - ខេត្តកំពង់ឆ្នាំង មាន ១ មណ្ឌល :

១–មណ្ឌលវិ. ព្រះបាទសុរាម្រិត ៨ បន្ទប់

X - ខេត្តពោធិ៍សាត់ មាន ១ មណ្ឌល :

១–មណ្ឌលរិៈពោធិសាត់ ៦ បន្ទប់ក្នុងនោះមាន បំ.រិ. ៤ នាក់

XI - ខេត្តបាត់ដំបង មាន ១ មណ្ឌល :

១–មណ្ឌលរិ.ព្រះមុនីវង្ស ៣៧ បន្ទប់ ក្នុងនោះបំ.រិ.៣បន្ទប់ និង ស្វ័យរិន ៤ បន្ទប់

XII - ខេត្តបន្ទាយមានជ័យ មាន ១ មណ្ឌល :

១–មណ្ឌលរិ.សម្តេចឪ ១៤ បន្ទប់ក្នុងនោះបំ.រិ.១ បន្ទប់

XIII - ខេត្តកំពង់ធំ មាន ១ មណ្ឌល :

១–មណ្ឌលរិ.កំពង់ធំ ២២ បន្ទប់ ក្នុងនោះបំ.រិ.១ បន្ទប់

XIV - ខេត្តកំពង់ចាម មាន ១ មណ្ឌល :

១–មណ្ឌល រិ.ព្រះសីហនុ ៥១ បន្ទប់ ក្នុងនោះបំ.រិ. ១ បន្ទប់

XV - ខេត្តក្រចេះ មាន ១ មណ្ឌល :

១–មណ្ឌលរិ.ព្រះមហាក្សត្រីយានីកុសមៈ ៩ បន្ទប់ ស្វ័យរិន ១ បន្ទប់

XVI - ខេត្តសៀមរាប មាន ១ មណ្ឌល :

១–មណ្ឌលអនុរិ.អង្គរ ១៨ បន្ទប់ ក្នុងនោះបំ.រិ. ១ បន្ទប់

XVII - ខេត្តស្ទឹងត្រែង មាន ១ មណ្ឌល :

១–មណ្ឌលរិ.ព្រះរាជបូជនីយកិច្ច ១ បន្ទប់

XVIII - ខេត្តកោះកុង មាន ១ មណ្ឌល :

១–មណ្ឌលរិ.កោះកុង ២ បន្ទប់

XIX - ខេត្តព្រះវិហារមាន ១ មណ្ឌល :

១–មណ្ឌលរិ.ត្បែងមានជ័យ ១ បន្ទប់

XX - ខេត្តរតនគិរី មាន ១ មណ្ឌល :

១–មណ្ឌលរិ.សម្តេចឪ–សម្តេចម៉ែ ១ បន្ទប់

ប្រការ ២ : ប្រធានមន្ទីរអប់រំយុវជននិងកីឡាខេត្ត–ក្រុង និងនាយកគ្រឹះស្ថានសិក្សាដែល គ្រឹះស្ថានសិក្សារបស់ខ្លួន ត្រូវយកធ្វើជាមណ្ឌលប្រលងមានភារៈកិច្ច រៀបចំមណ្ឌល ប្រលង សៀវភៅកំណត់រូបថតបេក្ខជន បញ្ជីផ្សេងៗ និង សំភារៈចាំបាច់សំរាប់

ការប្រព្រឹត្តិទៅនៃការប្រលងអោយ ហើយស្រេចមុនបើកសម័យប្រលង ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានអប់រំក្រៅប្រពន្ធ័ ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងអប់រំយុវជន និង កីឡា ត្រូវអនុវត្តភារកិច្ចរៀងៗ ខ្លួន ដើម្បីអោយបានសំរេចតាមប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងបរិស្ថាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១០៥៧ ប.ស្ថ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ**នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

– បានឃើញច្បាប់ស្តីពីការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ កក្កដា ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

– បានឃើញព្រះរាជក្រម នស.រកម ០១៩៦ ២១ ស្តីពីប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងបរិស្ថាន ចុះថ្ងៃទី២៤–០១–៩៦

-យោងសំណើររបស់នាយកដ្ឋានអប់រំ និងពតិមាន លេខ០៤៨អព.បស្ត ចុះថ្ងៃទី ១៨-៤-៩៦

-ពិនិត្យលើការចាំបាច់របស់នាយកដ្ឋានអប់រំពតិមាន

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការថ្នាក់ការិយាល័យចំណុះអោយនាយកដ្ឋានអប់រំនិងពតិមាន ដូចរាយឈ្មោះខាងក្រោម :

-លោកស្រី **ខេង លនគី** ជាប្រធានការិយាល័យរដ្ឋបាល

-លោកស្រី **សរ ម៉ូរីន** ជាប្រធានការិយាល័យនិពន្ធ និងស្រាវជ្រាវ

-លោក **ឈុំម និមល** ជាប្រធានការិយាល័យពតិមាន

-លោក **តេ រិទ្ធី** ជាអនុប្រធានការិយាល័យពតិមាន

-លោកស្រី **ឡុង សុខាបូនី** ជាអនុប្រធានការិយាល័យពតិមាន

-លោក **ម៉ក់ ស៊ីដេត** ជាអនុប្រធានការិយាល័យអប់រំ

-លោក **រាត់ សុទ្ធ** ជាអនុប្រធានការិយាល័យពិពន្ធ និងស្រាវជ្រាវ

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានកែសម្រួលតាមតួនាទីភារកិច្ចថ្មីរបស់ខ្លួន ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយក មន្ទីរ អង្គភាពពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ម៉ុក ម៉ារ៉េត

* * *

៦– ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១៨ ប្រក.វវស.មុ

ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យប្រធានបទសម្រាប់
ប្រឡងបញ្ចប់បរិញ្ញាជំនាន់ទី ២ ឆ្នាំ សិក្សា ១៩៩៥–៩៦
របស់មហាវិទ្យាល័យស្ថាបត្យកម្ម និង នគរោបនីយវិទ្យា
នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

–តាមសំណើរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ ដើម្បីត្រួតពិនិត្យប្រធានបទសម្រាប់ការប្រឡងបញ្ចប់បរិញ្ញាជំនាន់ ទី២ នៃមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រ សិល្បៈ ។

ប្រការ ២ : គណៈកម្មការរួមមានសមាសភាពដូចខាងក្រោម :

១–លោក **ឌុយ គឿន**	ប្រធាន
២–លោក **គឿង សុគន្ធ**	អនុប្រធានអចិន្ត្រៃយ៍
៣–អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ កុលឆ័ត**	សមាជិក
៤–លោកសាស្ត្រាចារ្យ **សាគូ**	សមាជិក

៥-លោកសាស្ត្រាចារ្យ**និច ទិនណូ** សមាជិក

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាង

* * *

៧-ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៨៦

សេចក្តីសំរេចលេខ ១៣៣/៨៦ កធស

ស្តីពីការអនុញ្ញាតអោយសាងសង់វិហារ

ឥស្លាមតួមិន្ទ្រាទី ២ ឃុំទ្រា ស្រុកក្រូចឆ្មារ

ខេត្តកំពង់ចាម

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦-១៩ ចុះថ្ងៃទី២៤.០១.៩៦
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២

ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា

-បានឃើញសំណើសុំសាងសង់វិហារឥស្លាម ឃុំទ្រា ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយសាងសង់វិហារឥស្លាមភូមិទ្រាទី ២ ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

ប្រការ ២ : វិហារឥស្លាមនេះត្រូវបានអនុញ្ញាតអោយសាសនិកនៃឥស្លាមគោរពប្រតិបត្តិផ្សព្វផ្សាយតាមជំនឿ ប្រពៃណីសាសនាឥស្លាមដោយអនុវត្តអោយបានត្រឹមត្រូវតាមគម្ពីគួរអាន និងហាទេស ។

ប្រការ ៣ : វិហារឥស្លាមនេះ ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិទាំងឡាយរបស់ក្រសួងធម្មការ និង សាសនា ។ មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិ សេរីភាពជំនឿសាសនាដទៃ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងទំនាក់ទំនងអោយបានល្អប្រសើរជាមួយរដ្ឋអំណាច និង ស្ថាប័នពាក់ព័ន្ធ ។

ប្រការ ៤ : រាល់ការអនុវត្តន៍ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច នាយកដ្ឋានសាសនា និង សាសនិក នៃ វិហារឥស្លាមភូមិទ្រាទី ២ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះ មានអនុភាពគតិយុត្តិចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ហត្ថលេខានិងត្រា

ហឿន វណ្ណារិត្ន

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៩៧៥ រៀល